00651603

E65/1

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 16 / 03 / 2011
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**អង្គជំនុំជម្រះសាលាដំបូង** **សាធារណៈ / Public**

**ជូនចំពោះ:** មេធាវីការពារ អៀង សារី

កាលបរិច្ឆេទ: ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១១

**ពី:** ចៅក្រម **និល ណុន** ប្រធានអង្គជំនុំជម្រះសាលាដំបូង និង លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** ភាគីទាំងអស់នៃសំណុំរឿងលេខ ០០២ និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** សេចក្តីសម្រេចលើសំណើរបស់ អៀង សារី ស្នើសុំដាក់សំណើសុំឱ្យមាន “ការបញ្ជាក់ថា គាត់នឹងត្រូវបានអនុញ្ញាតឱ្យបង្ហាញនូវទឡ្ហីករណ៍ផ្ទាល់មាត់ នៅពេលសវនាការបឋមស្តីអំពីអញ្ញត្រកម្មនីមួយៗរបស់គាត់”

អង្គជំនុំជម្រះសាលាដំបូងបានឃើញសំណើរបស់មេធាវីការពារក្តី អៀង សារី ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១១ ដាក់មកមន្ត្រីជាន់ខ្ពស់ នៃអង្គជំនុំជម្រះសាលាដំបូង ដែលស្នើសុំដាក់តែជាភាសាអង់គ្លេសប៉ុណ្ណោះ នៅដំណាក់កាលដំបូង នូវសំណើដែលមានចំនួន ១៥៩ទំព័រ សុំឱ្យមានការបញ្ជាក់ថា អៀង សារី នឹងត្រូវបានអនុញ្ញាតឱ្យបង្ហាញនូវទឡ្ហីករណ៍ផ្ទាល់មាត់ នៅពេលសវនាការបឋម ស្តីអំពីអញ្ញត្រកម្មនីមួយៗរបស់គាត់។ មេធាវីការពារក្តី អៀង សារី ទទួលស្គាល់ថា “ទោះបីជាពុំមានកាលបរិច្ឆេទពិតប្រាកដក្នុងការដាក់សំណើនេះយ៉ាងណាក៏ដោយ យើងយល់ឃើញថា សំណើនេះគួរត្រូវបានដាក់ និងពិចារណាឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដោយសារតែយើងត្រូវការឱ្យមានការបញ្ជាក់ទៅលើបញ្ហាដែលបានលើកឡើងនៅក្នុងសំណើ និងដើម្បីឱ្យយើងទទួលបាននូវព័ត៌មានដែលបានស្នើសុំនៅក្នុងសំណើនោះ មុនកិច្ចប្រជុំរៀបចំសវនាការ”។ សំណៅចម្លងដែលបានប្រគល់ជូនជាមុន ត្រូវបានភ្ជាប់មកជាមួយសំណើនេះ ដើម្បីជាការគួរសម។

នៅតែមានការស្នើសុំដាក់សំណើ ទោះបីជាអង្គជំនុំជម្រះបានបញ្ជាក់កាលពីលើកមុនហើយថា សេចក្តីបង្គាប់បន្ថែមស្តីពីអញ្ញត្រកម្ម រួមទាំងការកំណត់ពេលវេលា និងសារណាដែលត្រូវដាក់បន្ថែម នឹងត្រូវប្រកាសនៅពេលក្រោយយ៉ាងណាក៏ដោយ (E/35) ។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីរួចហើយ ថាតើសំណើណាខ្លះដែលនឹងត្រូវយកមកធ្វើការពិចារណានៅពេលសវនាការបឋម និងសំណើណាខ្លះដែលនឹងត្រូវស្តាប់ដោយផ្ទាល់មាត់ ឬសំណើណាខ្លះដែលនឹងត្រូវយកទៅពិចារណានៅពេលក្រោយ។

អង្គជំនុំជម្រះអនុញ្ញាតឱ្យដាក់សំណើនេះតែមួយភាសាប៉ុណ្ណោះ។ ដោយសារតែពុំមានមូលដ្ឋានផ្លូវច្បាប់ អាស្រ័យហេតុនេះ អង្គជំនុំជម្រះ ៖

ក. ណែនាំដល់អង្គភាពបកប្រែភាសាមិនឱ្យបកប្រែឯកសារខាងលើជាភាសាខ្មែរ និងភាសាបារាំង។

ខ. ស្នើដល់ភាគីទាំងអស់មិនឱ្យឆ្លើយតបទៅនឹងសំណើសុំនេះ។

គ. បញ្ជូនបញ្ហានេះទៅអង្គភាពគាំពារការពារក្តីដើម្បីធ្វើការត្រួតពិនិត្យ ហើយដោយផ្អែកតាមសិទ្ធិអំណាចរបស់ខ្លួន អង្គភាពនេះអាចបដិសេធនូវការបង់ប្រាក់សម្រាប់ការងារដែលបានបំពេញ ក្នុងករណីដែលការងារនោះ "មិនមានភាពចាំបាច់ និងមិនសមស្រប" (មាត្រា ១០ នៃការណែនាំអំពីជំនួយផ្នែកច្បាប់នៅ អ.វ.ត.ក) ហើយដោយផ្អែកតាមវិធាន១១-២(ជ) អង្គភាពនេះមានសមត្ថកិច្ចក្នុងការ "ត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញការងារនៃគ្រប់កិច្ចសន្យាទាំងអស់ (រវាងអង្គភាពនេះជាមួយនឹងមេធាវីការពារជនជាប់ចោទ) និងអនុញ្ញាតឱ្យផ្តល់ប្រាក់កម្រៃស្របតាមលទ្ធផលការងារ ដូចមានចែងក្នុងបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្តី"។

ឃ. បញ្ជូនសំណៅចម្លងនៃអនុស្សរណៈនេះទៅឱ្យប្រធានស្តីទី និងអនុប្រធានការិយាល័យរដ្ឋបាលដើម្បីជ្រាបជាព័ត៌មាន។

នេះគឺជាការឆ្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងសំណើ អនុលោមតាមវិធានផ្ទៃក្នុង ៨០*ស្ទួន*(៣) និង ៨៩។

អង្គជំនុំជម្រះជម្រាបបន្ថែមទៀតថា ការអនុវត្តនាពេលបច្ចុប្បន្ននេះ នូវការដាក់សំណើដែលមានច្រើនទំព័រ ទាក់ទិនទៅនឹងបញ្ហារដ្ឋបាល នឹងត្រូវយកទៅពិភាក្សានៅកិច្ចប្រជុំរៀបចំសវនាការ។